ឧបសម្ព័ន្ធទី៦៖ លិខិតជូនដំណឹងពីការបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) នៅខេត្ត

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ម្ចាស់ ឬនាយកក្រុមហ៊ុន ៖** **សាងវ៉ូ (ខេមបូឌា) ខូ អិលធីឌី**

លេខបញ្ជីពាណិជ្ជកម្ម ៖ ០០០១១២៧៧

លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស. ៖ ១០០០១១៧.ង

លេខគណនីធនាគារ ៖ ០០០០០២១៨៩ (Advanced Bank of Asia Ltd.

អាសយដ្ឋាន ៖ ភូមិ ត្រពាំងវែង និងធ្លក ឃុំ ត្រពាំងគង ស្រុក សំរោងទង ខេត្ត កំពង់ស្ពឺ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខ ៖ ០១២ ៣០២ ២១២ អ៊ីមែល (E-mail)៖ engchhun@sangwoo.com.kh

## សូមគោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**តាមរយៈ** ៖ លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ស្ពឺ

**កម្មវត្ថុ** ៖ ការបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញមុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ)

**យោង** ៖ លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ លេខៈ២៥៨៧/២០ កប/កស្គ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថាៈ ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំបានទទួលការអនុញ្ញាតឲ្យព្យួរកិច្ចសន្យាការងារកម្មករ និយោជិតរយៈពេលចំនួន ៦១ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ។ ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញមុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ) ដល់កម្មករ និយោជិតចំនួន ៤៥៧ នាក់ ក្នុងចំណោមកម្មករ និយោជិត ដែលបានសុំព្យួរកិច្ចសន្យាការងារសរុបចំនួន ១៥៥៨នាក់ ចាប់ពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ ខាងមុខនេះតទៅ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយសេចក្តីអនុគ្រោះ ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃអង្គារ ១១រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅកំពង់ស្ពឺ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២០

ហត្ថលេខា និងត្រា

ម្ចាស់ ឬនាយក

សាងវ៉ូ (ខេមបូឌា) SANGWOO (CAMBODIA) CO., LTD.

Mr. JISOO JANG

សូមភ្ជាប់មកជាមួយៈ
- លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) ចំនួន ៣ច្បាប់ និងជា Soft Copy (Ms Excel)ទៅE-mail:suspension@nea.gov.kh